# ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/០៧ ចុះថ្ងៃទី១១/០១/១៩៩៩ ច្បាប់ស្តីពីការកំណត់ និងគ្រប់គ្រងព្រៃឈើតំបន់ដីជំរាល

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និគរោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៨ ។

## ត្រាស់បង្គាប់

**មាត្រា១.-**

ត្រូវបានបង្កើតឱ្យមានការកំណត់ និងការគ្រប់គ្រងព្រៃតំបន់ដីជំរាលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

ដីជំរាលជាជួរនៃតំបន់ដីខ្ពស់ ដែលផ្នែកសងខាងនៃតំបន់នោះ មានចរន្តទឹកហូរចាក់ទៅក្នុងអូរ ស្ទឹង បឹង ទន្លេ ឬ សមុទ្រ ។

**មាត្រា៣.-**

កំណត់ និងគ្រប់គ្រងព្រៃឈើ តំបន់ដីជំរាលក្នុងគោលបំណង ៖

ក- ការពារការហូរច្រោះ ។

ខ- កាត់បន្ថយល្បឿនចរន្តទឹកក្នុងតំបន់ដីជំរាល ។

គ- រក្សានិយតភាពប្រភពទឹកក្នុងដី ។

ឃ- ទប់ទល់ការបាត់បង់ជីវជាតិរបស់ដី ។

ង- រក្សានូវសុក្រឹតភាពនៃប្រភព និងគុណភាពទឹក ។

ច- គាំពារជីវៈចំរុះ ។

ឆ- ធ្វើឱ្យមានលំនឹងដល់បរិស្ថានធម្មជាតិ ។

**មាត្រា៤.-**

កំណត់ផ្ទៃដីព្រៃឈើតំបន់ដីជំរាល ដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៥.-**

ផ្ទៃដីព្រៃឈើក្នុងតំបន់ដីជំរាលអាចនឹងកែប្រែពង្រីងបន្ថែម ដោយផ្អែកទៅលើព័ត៌មានវិទ្យាសាស្ត្រ

និងស្ថានភាពជាក់ស្តែងនៅពេលអនាគត ។

មាត្រា៦.-

ការអភិវឌ្ឍន៍ ការធ្វើអាជីវកម្មផលអនុផលព្រៃឈើគ្រប់ប្រភេទនៅតំបន់ដីជំរាលត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៧.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំគ្រប់គ្រង និងធ្វើការអភិវឌ្ឍន៍ព្រៃឈើតំបន់ដីជំរាលដូចចែងក្នុងមាត្រា២ ហើយមានសិទ្ធិធ្វើសហប្រតិបត្តិការជាមួយអន្តរក្រសួង អង្គការអន្តរជាតិ ឬ អង្គការក្រៅរដ្ឋាភិបាលលើបន្ទាត់នយោបាយព្រៃឈើ និងបច្ចេកទេស ។

មាត្រា៨.-

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៩.-